Disability Rights California

*California's protection & advocacy system*

# សិទ្ធិទទួលបានសត្វនាំផ្លូវនិងសត្វគាំពារផ្លូវចិត្តនៅក្នុងលំនៅដ្ឋាននិងទីសាធារណៈ – FAQ (សំណួរដែលសួរជាញឹកញាប់)

*ឯកសារបោះពុម្ពផ្សាយ#7155.06 Cambodian - ខែមិថុនា ឆ្នាំ2020*

ប្រសិនបើអ្នកមានពិការភាព កំពុងជួបប្រទះនូវបញ្ហាគ្មានទីជម្រក និងមានសត្វនាំផ្លូវ ច្បាប់អនុញ្ញាតឲ្យអ្នកយកវាមកជាមួយអ្នកនៅតាមទីសាធារណៈ និងនៅក្នុងលំនៅដ្ឋានរបស់អ្នក រួមទាំងនៅទីជម្រកសម្រាប់ជនគ្មានទីលំនៅផងដែរ។

ប្រសិនបើអ្នកមានសត្វគាំពារផ្លូវចិត្តក្រៅពីសត្វនាំផ្លូវ ក៏នៅមានច្បាប់ដែលអនុញ្ញាតឲ្យអ្នកយកវាមកជាមួយអ្នកនៅក្នុងលំនៅដ្ឋានរបស់អ្នក រួមទាំងនៅក្នុងទីជម្រកសម្រាប់ជនគ្មានទីលំនៅផងដែរ ប៉ុន្តែមិនមែននៅទីសាធារណៈនោះទេ។

ប្រើបញ្ជីសំណួរនិងចម្លើយនេះដើម្បីស្វែងយល់ពីច្បាប់ដែលអនុវត្តចំពោះអ្នក និងអំពីការលើកលែងទាំងឡាយណាដែលអនុវត្តចំពោះអ្នក។

សម្រាប់ឯកសារយោងខ្លីៗ សូមមើលផងដែរ “សត្វគាំពារផ្លូវចិត្តនិងសត្វនាំផ្លូវនៅទីសាធារណៈនិងលំនៅដ្ឋាន - ព្រឹត្តិបត្រព័ត៌មានខ្លីៗ។”

## តើច្បាប់អ្វីខ្លះដែលយកមកអនុវត្ត?

ចំណាំ៖ ផ្នែកនេះគឺមានបំណងផ្តល់ខ្លឹមសារសង្ខេបនៃច្បាប់ដែលអនុវត្តចំពោះសិទ្ធិជនពិការនៅទីសាធារណៈនិងលំនៅដ្ឋាន។ ផ្នែកបន្តបន្ទាប់ទាំងនេះដែលផ្តើមឡើងដោយ “តើអ្វីខ្លះត្រូវបានចាត់ទុកថាជាសត្វនាំផ្លូវ?” នឹងចាប់ផ្តើមផ្តល់នូវសំណួរនិងចម្លើយជាក់លាក់ថាតើអ្នកអាចនាំយកសត្វនាំផ្លូវឬសត្វគាំពារផ្លូវចិត្តមកជាមួយអ្នកនៅទីសាធារណៈ និង/ឬលំនៅដ្ឋានបានដែរឬអត់។

វាមានចង្កោមច្បាប់ផ្សេងៗ
គ្នាដែលរ៉ាប់រងលើសិទ្ធិជនពិការសម្រាប់ទីសាធារណៈនិងលំនៅដ្ឋាន។ ច្បាប់មួយចំនួនជាច្បាប់រដ្ឋ និងមួយចំនួនទៀតជាច្បាប់សហព័ន្ធ។

នេះគឺជាបញ្ជីរាយនាមច្បាប់សំខាន់ៗដែលរ៉ាប់រងលើសិទ្ធិជនពិការនៅតាមទីសាធារណៈ៖

- ច្បាប់ស្តីពីជនពិការអាមេរិក (ADA) មាត្រា II (រ៉ាប់រងលើស្ថាប័នរដ្ឋាភិបាលរដ្ឋនិងតំបន់ ស្ថាប័នសាធារណៈរបស់ AKA) និងមាត្រា III (រ៉ាប់រងលើផ្នែកពាណិជ្ជកម្ម) នៃ [ច្បាប់សហព័ន្ធ]
- ច្បាប់ស្តីពីសិទ្ធិពលរដ្ឋអ៊ុនរូហ៍របស់រដ្ឋកាលីហ្វ័រញ៉ា (California's Unruh Civil Rights Act) (រ៉ាប់រងលើផ្នែកអាជីវកម្ម)
- ច្បាប់ស្តីពីបុគ្គលដែលមានពិការភាពរបស់រដ្ឋកាលីហ្វ័រញ៉ា (California Disabled Persons Act) (រ៉ាប់រងលើផ្នែកអាជីវកម្ម)
- ក្រមរដ្ឋាភិបាលរដ្ឋកាលីហ្វ័រញ៉ា 11135 (Government Code 11135) (រ៉ាប់រងលើអ្នកទទួលបានមូលនិធិរដ្ឋ)

នេះគឺជាបញ្ជីរាយនាមច្បាប់សំខាន់ៗ
ដែលរ៉ាប់រងលើសិទ្ធិជនពិការនៅក្នុងលំនៅដ្ឋាន៖

- ច្បាប់វិសោធនកម្មស្តីពីលំនៅដ្ឋានស្មើភាពគ្នា (Fair Housing Amendments Act) [ច្បាប់សហព័ន្ធ] (រ៉ាប់រងលើទម្រង់លំនៅដ្ឋានភាគច្រើន រួមទាំងទីជម្រកសម្រាប់ជនគ្មានទីលំនៅផងដែរ)
- ផ្នែក 504 នៃច្បាប់ស្តីពីការស្តារនីតិសម្បទា (Rehabilitation Act) (រ៉ាប់រងលើអ្នកទទួលបានមូលនិធិសហព័ន្ធ) [ច្បាប់សហព័ន្ធ]
- ច្បាប់ស្តីពីបុគ្គលដែលមានពិការភាពរបស់រដ្ឋកាលីហ្វ័រញ៉ា (California Disabled Persons Act)
- ច្បាប់ស្តីពីលំនៅដ្ឋាននិងការងារស្មើភាពគ្នារបស់រដ្ឋកាលីហ្វ័រញ៉ា (California Fair Employment and Housing Act)

ចំណាំ៖ សិទ្ធិជនពិការនៅក្នុងលំនៅដ្ឋានសម្រាប់ជនគ្មានទីលំនៅអាចត្រូវបានរ៉ាប់រងទាំងចង្កោមនៃច្បាប់សហព័ន្ធនិងរដ្ឋមួយចំនួន ដោយអាស្រ័យទៅលើរបៀបដែលទីលំនៅត្រូវបានផ្តល់មូលនិធិ និងផ្នែកណាមួយនៃទីជម្រកដែលកំពុងត្រូវបានប្រើប្រាស់ ឬរបៀបចូលទៅប្រើប្រាស់វា (សម្រាប់ជាបន្ទប់ស្នាក់នៅពេលថ្ងៃ/មជ្ឈមណ្ឌលធនធាន ឬជាទម្រង់នៃលំនៅដ្ឋាន)។ ប៉ុន្តែអ្នកនៅតែអាចប្រើប្រាស់ FAQ នេះដើម្បីវាយតម្លៃថាតើវិធានអ្វីខ្លះដែលអនុវត្តចំពោះអ្នក ពេលវេលា និងរបៀបក្នុងការបង្ហាញប្រាប់អំពីពួកវា។

## តើអ្នកណាដែលត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិជនពិការ?

បុគ្គលដែលមានពិការភាព ត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិជនពិការ។ ជនពិការត្រូវបានកំណត់ខុសគ្នាបន្តិចបន្តួចនៅក្រោមច្បាប់សហព័ន្ធនិងរដ្ឋ ប៉ុន្តែជាទូទៅពួកគេៈ

1. មានភាពចុះខ្សោយផ្នែករាងកាយ និងផ្លូវចិត្ត
2. ដែលកំណត់
3. សកម្មភាពមុខងារសំខាន់ៗក្នុងជីវិត (MLA) មួយឬច្រើននៃបុគ្គល

ច្បាប់ស្តីពីសិទ្ធិពិការភាពរបស់រដ្ឋនិងសហព័ន្ធ និងច្បាប់របស់រដ្ឋកាលីហ្វ័រញ៉ា ទាំងអស់ ប្រើប្រាស់និយមន័យស្រដៀងគ្នានេះ លើងលែងត្រង់ថា ច្បាប់របស់រដ្ឋកាលីហ្វ័រញ៉ាមានភាពទូលំទូលាយជាង – ច្បាប់សហព័ន្ធតម្រូវឲ្យដែនកំណត់នៃ MLA មានភាព "ជាក់ស្តែង។"

បុគ្គលត្រូវបានការពារពីការរើសអើងផ្អែកលើមូលដ្ឋានពិការភាព ប្រសិនបើពួកគេៈ

1. មានភាពចុះខ្សោយផ្នែករាងកាយនិងផ្លូវចិត្តដែល [ជាក់ស្តែង - ប្រសិនបើច្បាប់សហព័ន្ធអនុវត្ត] កំណត់សកម្មភាពមុខងារសំខាន់ៗក្នុងជីវិតមួយឬច្រើន
2. មានប្រវត្តិធ្លាប់មានភាពចុះខ្សោយណាមួយ ឬ
3. ត្រូវបានចាត់ទុកថាមានភាពចុះខ្សោយណាមួយ។

## តើអ្វីខ្លះដែលត្រូវបានចាត់ទុកជាសកម្មភាពមុខងារសំខាន់ៗក្នុងជីវិត (MLA)?

ដូចគ្នាទៅនឹងនិយមន័យនៃពិការភាពដែរ និយមន័យនៃសកម្មភាពមុខងារសំខាន់ៗក្នុងជីវិត មានភាពខុសគ្នាបន្តិចបន្តួចនៅក្នុងចំណោមច្បាប់សហព័ន្ធនិងរដ្ឋទាំងអស់។ ប៉ុន្តែជាទូទៅ ពួកគេរួមមានជាអាទិ៍ៈ ការថែទាំខ្លួនឯង ការទទួលទាន ការគេង ការមើល ការស្តាប់ ការនិយាយ ការផ្តល់ស្មារតី ការគិត ការធ្វើការងារ ការដើរ ការឈរ ការដកដង្ហើម និងមុខងារសំខាន់ៗនៃរាងកាយដូចជាប្រព័ន្ធរំលាយអាហារ ប្រព័ន្ធផ្លូវដង្ហើម ប្រព័ន្ធឈាមរត់ ប្រព័ន្ធប្រសាទ និងមុខងារបន្តពូជ។

ដូចគ្នាទៅនឹងនិយមន័យនៃពិការភាពដែរ និយមន័យនៃ MLA របស់ច្បាប់រដ្ឋគឺមានភាពទូលំទូលាយជាងបន្តិចបន្តួច និងមានរៀបរាប់បន្ថែមអំពី MLA ថាមានកម្រិត ប្រសិនបើវាមានការលំបាកតាមរយៈភាពចុះខ្សោយផ្នែករាងកាយឬផ្លូវចិត្ត។

## តើអ្វីខ្លះដែលត្រូវបានចាត់ទុកថាជាសត្វនាំផ្លូវ?

"សត្វនាំផ្លូវ" គឺជាៈ

1. សត្វឆ្កែ

2. ដែលបានបង្ហឹកដោយផ្ទាល់
3. ដើម្បីបំពេញការងារឬកិច្ចការ
4. ដែលផ្តល់អត្ថប្រយោជន៍ដល់បុគ្គលដែលមានពិការភាព រួមទាំងរាងកាយ ឥន្ទ្រីយ៉ារម្មណ៍ ចិត្តសាស្ត្រ បញ្ញា ឬពិការភាពប្រភេទផ្សេងទៀត។

ចំណាំ៖ សត្វនាំផ្លូវ អាចត្រូវបានបង្ហឹកដោយអ្នកជំនាញ មិត្តភក្តិ សមាជិកគ្រួសារ ឬបុគ្គលដែលមានពិការភាព។

ចំណាំ៖ សត្វនាំផ្លូវ ក៏អាចរួមមានសត្វសេះតូចៗផងដែរ។ ទោះបីជានិយមន័យរបស់ច្បាប់ ADA ត្រូវបានកំណត់ត្រឹមតែទៅលើសត្វឆ្កែក៏ដោយ ក៏បទប្បញ្ញត្តិរបស់សហព័ន្ធចែងថា សត្វសេះតូចៗត្រូវតែអនុញ្ញាតឲ្យធ្វើជាសត្វនាំផ្លូវនៅទីសាធារណៈ ប្រសិនបើពួកវាត្រូវបាន
បង្ហឹកដោយផ្ទាល់ដើម្បីផ្តល់អត្ថប្រយោជន៍ដល់បុគ្គលដែលមានពិការភាព
និងអាចត្រូវបានគាំទ្រយ៉ាងសមស្រប។

### តើអ្វីខ្លះដែលអាចចាត់ទុកជាសត្វគាំពារផ្លូវចិត្ត?

សត្វគាំពារផ្លូវចិត្តគឺជា៖

1. សត្វទាំងឡាយណា
2. ដែលកាត់បន្ថយផលប៉ះពាល់
3. នៃពិការភាពរបស់បុគ្គល
4. តាមរយៈការផ្តល់ការលួងលោមឬការគាំពារ។

### តើឧទាហរណ៍មួយចំនួននៃការងារនិងកិច្ចការដែលសត្វនាំផ្លូវអាចត្រូវបានបង្ហឹកឲ្យបំពេញមានអ្វីខ្លះ?

ការបើកភ្លើង ការរើសវត្ថុឡើង ការបង្កើតរំញោច
កាយវិញ្ញាណនិងការព្យាបាលដោយកម្លាំងសង្កត់ខ្លាំងលើរាងកាយដល់ម្ចាស់សត្វ
ការការពារឬការរំខានពីអាកប្បកិរិយាកើតឡើងភ្លាមៗឬបង្កគ្រោះថ្នាក់
ការក្រើនរំលឹកឲ្យបុគ្គលលេបថ្នាំ
និងការទាញបុគ្គលដែលវង្វេងទិសដៅចេញពីស្ថានភាពគ្រោះថ្នាក់។

ចំណាំ៖ មិនមានលក្ខខណ្ឌតម្រូវជាក់លាក់ទៅលើចំនួនឬប្រភេទការងារ
ដែលសត្វនាំផ្លូវត្រូវផ្តល់ឲ្យសម្រាប់អត្ថប្រយោជន៍
នៃបុគ្គលដែលមានពិការភាពនោះទេ។ លក្ខខណ្ឌតម្រូវតែមួយគត់ដើម្បីក្លាយជាសត្វនាំផ្លូវគឺ សត្វឆ្កែត្រូវបានបង្ហឹកដោយផ្ទាល់ ដើម្បីផ្តល់អត្ថប្រយោជន៍ដល់បុគ្គលដែលមានពិការភាព។

### តើខ្ញុំចាំបាច់ត្រូវធ្វើអ្វីមួយដែរឬទេ ដើម្បីកំណត់សម្គាល់ថា សត្វឆ្កែរបស់ខ្ញុំជាសត្វនាំផ្លូវ?

ទេ។ ច្បាប់ ADA មិនតម្រូវឲ្យសត្វឆ្កែនាំផ្លូវចុះឈ្មោះជាសត្វនាំផ្លូវ ឬពាក់ស្លាក ឬអាវកាក់ពិសេសដើម្បីកំណត់សម្គាល់ថាពួកវាជាសត្វនាំផ្លូវទេ។ ច្បាប់របស់រដ្ឋកាលីហ្វ័រញ៉ា បង្គាប់ឲ្យនាយកដ្ឋានគ្រប់គ្រងសត្វក្នុងស្រុក ចេញនូវស្លាកសម្គាល់អត្តសញ្ញាណទៅមនុស្សដែលប្រើប្រាស់ និងបង្វឹកសត្វនាំផ្លូវ។ ប៉ុន្តែ លើកលែងតែសត្វឆ្កែគឺជាសត្វនាំផ្លូវដែលស្ថិតក្នុងការបង្វឹក (មើលការពិភាក្សាខាងក្រោម) ពុំនោះទេ ស្លាកសញ្ញាមិនតម្រូវឲ្យមាននោះទេ និង មិនបញ្ជាក់ថាសត្វណាមួយគឺជាសត្វនាំផ្លូវនៅក្រោមច្បាប់ឡើយ។

### តើខ្ញុំមានសិទ្ធិអ្វីខ្លះ នៅពេលខ្ញុំព្យាយាមយក សត្វនាំផ្លូវរបស់ខ្ញុំមកជាមួយនៅទីសាធារណៈ?

មាត្រា II និង III នៃច្បាប់ ADA ចែងថា ម្ចាស់សត្វនាំផ្លូវគឺត្រូវបានអនុញ្ញាតឲ្យមាន សត្វនាំផ្លូវអមដំណើរជាមួយពួកគេនៅទីសាធារណៈ (មើលសំណួរខាងក្រោមសម្រាប់ការពន្យល់ពី “ទីសាធារណៈ”) ដរាបណាគ្មានករណី លើកលែងណាមួយត្រូវបានអនុវត្ត (មើលខាងក្រោម “តើនៅពេលណាដែល សត្វនាំផ្លូវរបស់ខ្ញុំត្រូវបានបដិសេធមិនឲ្យចូលទៅកាន់ទីសាធារណៈ?”)

### តើអ្វីខ្លះត្រូវបានចាត់ទុកថាជាទីសាធារណៈ?

ទីសាធារណៈគឺជាស្ថាប័នអាជីវកម្មនិងស្ថាប័នរដ្ឋាភិបាល ដែលបើកចំហសម្រាប់សាធារណៈជន។

អាជីវកម្មរួមមានភោជនីយដ្ឋាន សណ្ឋាគារ រោងកុន ហាងទំនិញ ការិយាល័យវេជ្ជសាស្ត្រនិងមន្ទីរពេទ្យ។

ស្ថាប័នរដ្ឋាភិបាលគឺជាកន្លែងដែលប្រតិបត្តិដោយរដ្ឋឬរដ្ឋាភិបាលក្នុងតំបន់ ដូចជាអគាររដ្ឋាភិបាល មធ្យោបាយធ្វើដំណើរសាធារណៈ និងឧទ្យានសាធារណៈ។

ចំណាំ៖ ស្ថាប័នរដ្ឋាភិបាល ក៏អាចរួមមានទីជម្រកសម្រាប់ជនគ្មានទីលំនៅដែល គ្រប់គ្រងដោយរដ្ឋាភិបាលក្នុងតំបន់ផងដែរ។

ចំណាំ៖ ទីសាធារណៈក៏អាចរួមមានទីជម្រកសម្រាប់ជនគ្មានទីលំនៅ បន្ទប់ស្នាក់នៅពេលថ្ងៃ បណ្ណាល័យ ធនាគារអាហារ និងមជ្ឈមណ្ឌលសម្រាប់មនុស្ស ចាស់ ដោយសារតែពួកវាបើកដំណើរការសម្រាប់សាធារណៈជនទាំងអស់។

### តើខ្ញុំចាំបាច់ត្រូវធ្វើអ្វីខ្លះ នៅពេលដែលខ្ញុំព្យាយាមចូលទៅទីសាធារណៈជាមួយ នឹងសត្វនាំផ្លូវរបស់ខ្ញុំ/តើសំណួរអ្វីខ្លះដែលអាចនឹងត្រូវបាន សួរមកកាន់ខ្ញុំ?

ប្រសិនបើអ្នកមានសត្វនាំផ្លូវ នោះច្បាប់នឹងការពារសិទ្ធិរបស់អ្នកក្នុងការចូលទៅ កាន់ទីសាធារណៈជាមួយវា។ ដូច្នេះ រឿងតែមួយគត់ដែលអ្នកចាំបាច់ត្រូវធ្វើ

គឺចូលទៅទីសាធារណៈ។ ម្យ៉ាងទៀត ប្រសិនបើតម្រូវការសត្វមានភាពពិតប្រាកដ ឬជាក់ស្តែង នោះអ្នកអាចនឹងមិនត្រូវបានសាកសួរសំណួរណាមួយឡើយ។

ប៉ុន្តែ នៅពេលដែលនិយោជិកឬអ្នកតំណាងនៃទីផ្សាសាធារណៈ មិនដឹងច្បាស់ថាសត្វរបស់អ្នកគឺជាសត្វនាំផ្លូវនោះទេ ពួកគេនឹងអាចសាកសួរអ្នកដែលជាម្ចាស់សត្វ៖

1) តើសត្វត្រូវបានតម្រូវឲ្យមាន ដោយសារតែពិការភាពរបស់ម្ចាស់សត្វមែនឬទេ? ហើយ
2) តើការងារឬកិច្ចការអ្វីដែលសត្វត្រូវបានបង្វឹកឲ្យបំពេញ?

ចំណាំ៖ ក្រោមច្បាប់របស់រដ្ឋកាលីហ្វ័រញ៉ា
ការក្លែងបន្លំថាសត្វឆ្កែគឺជាសត្វនាំផ្លូវដែលបានបង្វឹក គឺជាបទល្មើសមជ្ឈិម ដែលមានការផ្តន្ទាទោសជាប់ពន្ធនាគាររហូតដល់ប្រាំមួយខែ
និង/ឬពិន័យជាប្រាក់រហូតដល់ $1,000 (ក្រមព្រហ្មទណ្ឌ ផ្នែក 365.7(a))។

## តើនៅពេលណាដែលសត្វនាំផ្លូវរបស់ខ្ញុំអាចត្រូវបានបដិសេធមិនឲ្យចូលទៅកាន់ទីសាធារណៈ?

ទីសាធារណៈ មិនចាំបាច់តម្រូវឲ្យអនុញ្ញាតបើកផ្លូវចេញចូលដល់សត្វនាំផ្លូវទាំងឡាយដែល៖

1. បង្កការគំរាមកំហែងដោយផ្ទាល់ទៅអ្នកដទៃ
2. មិនស្ថិតនៅក្រោមការថែទាំនិងគ្រប់គ្រងរបស់ម្ចាស់សត្វ ឬ
3. នឹងធ្វើការកែប្រែជាមូលដ្ឋាននូវលក្ខណៈនៃទំនិញ សេវាកម្ម ឬកម្មវិធីដែលផ្តល់ឲ្យដោយស្ថាប័នអាជីវកម្ម និងស្ថាប័នរដ្ឋាភិបាល។

## តើអ្វីខ្លះត្រូវបានចាត់ទុកជាការគំរាមកំហែងដោយផ្ទាល់?

ការគំរាមកំហែងដោយផ្ទាល់គឺជា៖

1. ហានិភ័យធ្ងន់ធ្ងរចំពោះសុខភាពឬសុវត្ថិភាពរបស់អ្នកដទៃ
2. ដែលមិនអាចត្រូវបានលុបបំបាត់ដោយការកែសម្រួលគោលនយោបាយ ការអនុវត្ត ឬនីតិវិធី ឬការផ្តល់ជំនួយឬសេវាកម្មបន្ថែម។

ឧទាហរណ៍ សត្វឆ្កែដែលខាំដោយគ្មានការពន្យរឲ្យខាំ អាចនឹងបង្ហាញពីការគំរាមកំហែងដោយផ្ទាល់។

ចំណាំ៖ ការបដិសេធសត្វនាំផ្លូវដោយផ្អែកទៅលើការគំរាមកំហែងដោយផ្ទាល់ ត្រូវតែផ្អែកទៅលើអាកប្បកិរិយាជាក់ស្តែងនៃសត្វណាមួយ

មិនមែនលើការប៉ាន់ស្មានឬការកំណត់អំពីលក្ខណៈដែលសត្វ ឬពូជសត្វនោះ អាចនឹងបង្ហាញឲ្យឃើញនោះទេ។

ហើយ នៅក្នុងការកំណត់ថាតើមានការគំរាមកំហែងដោយផ្ទាល់ឬអត់ ការវាយតម្លៃលក្ខណៈបុគ្គលត្រូវតែធ្វើឡើង
ដោយផ្អែកទៅលើការវិនិច្ឆ័យសមស្របដែលពឹងផ្អែកទៅលើចំណេះដឹងផ្នែកវេជ្ជសាស្ត្របច្ចុប្បន្ន ឬផ្អែកលើភស្តុតាងជាក់ស្តែងបំផុតដែលមាន។
ការវាយតម្លៃគប្បីវាយតម្លៃលើៈ លក្ខណៈ រយៈពេល និងភាពធ្ងន់ធ្ងរនៃហានិភ័យ លទ្ធភាពដែលពិតជាអាចកើតមានរបួស ហើយតើការកែសម្រួលសមស្របនៃគោលនយោបាយ ការអនុវត្ត ឬនីតិវិធី ឬការផ្តល់ជំនួយឬសេវាកម្មបន្ថែមនឹងកាត់បន្ថយហានិភ័យដែរឬអត់។

## តើមានអ្វីអាចកើតឡើង ប្រសិនបើសត្វនាំផ្លូវរបស់ខ្ញុំមិនស្ថិតនៅក្រោមការថែទាំនិងគ្រប់គ្រងរបស់ខ្ញុំ?

បុគ្គលដែលមានពិការភាព អាចត្រូវបានសាកសួរដើម្បីយកសត្វនាំផ្លូវរបស់ពួកគេចេញពីទីតាំង ប្រសិនបើសត្វមិនស្ថិតនៅក្រោមការគ្រប់គ្រង ហើយម្ចាស់សត្វមិនចាត់វិធានការដែលមានប្រសិទ្ធភាពដើម្បីគ្រប់គ្រងវា ឬប្រសិនបើសត្វមិនត្រូវបានបង្ហាត់ឲ្យនោមឬចុះនៅក្រៅអគារទេ។
ទំនួលខុសត្រូវដើម្បីគ្រប់គ្រងនិងថែទាំសត្វនាំផ្លូវមិនធ្លាក់ទៅលើស្ថាប័នអាជីវកម្មនិងស្ថាប័នរដ្ឋាភិបាលដែលផ្តល់ការអនុញ្ញាតឲ្យចេញចូលទីតាំងនោះទេ។

ជាទូទៅ សត្វនាំផ្លូវត្រូវតែមានខ្សែបង្ហៀរ ចំណង ឬខ្សែចំណងផ្សេងទៀត។ ប៉ុន្តែប្រសិនបើម្ចាស់សត្វមិនអាចប្រើខ្សែបង្ហៀរ ចំណង ឬខ្សែចំណងផ្សេងទៀតព្រោះតែពិការភាព ឬប្រសិនបើការប្រើខ្សែចំណងអាចនឹងប៉ះពាល់ដល់សុវត្ថិភាពរបស់សត្វនាំផ្លូវ ការបំពេញការងារឬកិច្ចការប្រកបដោយប្រសិទ្ធភាព នោះម្ចាស់សត្វអាចប្រើមធ្យោបាយផ្សេងដើម្បីឲ្យសត្វស្ថិតក្រោមការគ្រប់គ្រង។

## តើ "ការកែប្រែជាមូលដ្ឋាននូវលក្ខណៈនៃទំនិញ សេវាកម្ម ឬកម្មវិធីដែលផ្តល់ឲ្យនៅទីតាំងណាមួយ" មានន័យដូចម្តេច?

ឧទាហរណ៍ ការស្នើសុំឲ្យបុគ្គលិកនៃបន្ទប់ស្នាក់នៅពេលថ្ងៃក្នុងទីជម្រកសម្រាប់ជនគ្មានទីលំនៅធ្វើការផ្តល់ចំណី បណ្តើរ ឬសម្អាតនៅពីក្រោយសត្វនាំផ្លូវ អាចនឹងត្រូវបានចាត់ទុកថាជាការកែប្រែជាមូលដ្ឋានចំពោះសេវាកម្មដែលបុគ្គលិកទីជម្រកសម្រាប់ជនគ្មានទីលំនៅផ្តល់ឲ្យ។

## តើខ្ញុំអាចយកសត្វនាំផ្លូវរបស់ខ្ញុំចូលទៅមន្ទីរពេទ្យឬមណ្ឌលថែទាំសុខភាពដទៃទៀតជាមួយខ្ញុំបានដែរឬទេ?

បាទ/ចាស។ មន្ទីរពេទ្យឬមណ្ឌលថែទាំសុខភាពដទៃទៀត ត្រូវបានចាត់ទុកដូចជាអាជីវកម្មនិងទីសាធារណៈដទៃទៀតដែរ សម្រាប់គោលបំណងដែលអាចឲ្យសត្វនាំផ្លូវចេញចូលទីតាំងបាន។ សត្វនាំផ្លូវត្រូវតែអនុញ្ញាតនៅគ្រប់ទីកន្លែងក្នុងមន្ទីរពេទ្យដែលបុគ្គលិកថែទាំសុខភាព អ្នកជំងឺ និងអ្នកមកសួរសុខទុក្ខទទួលបានការអនុញ្ញាតឲ្យចូល។ នេះរួមមានបន្ទប់របស់អ្នកជំងឺនិងទីកន្លែងសាធារណៈដទៃទៀតនៃអង្គភាពសុខភាពផ្លូវចិត្តរបស់អ្នកជំងឺក្នុងនិងក្រៅមន្ទីរពេទ្យ រួមទាំងមណ្ឌលសុខភាពផ្លូវចិត្តដែលបានចាក់សោផងដែរ។ អ្នកជំងឺត្រូវតែអាចថែទាំសត្វ ឬត្រូវតែរៀបចំឲ្យនរណាម្នាក់ផ្សេងទៀតថែទាំសត្វនោះ ប្រសិនបើចាំបាច់។

ប៉ុន្តែ សត្វនាំផ្លូវអាចនឹងត្រូវបានបដិសេធមិនឲ្យនៅក្នុងទីតាំងដែលការចេញចូលត្រូវបានរឹតបន្តឹងនៅមន្ទីរពេទ្យដែលប្រើវិធានការគ្រប់គ្រងការឆ្លងជំងឺទូទៅ ដូចជាបន្ទប់វះកាត់និងបន្ទប់ព្យាបាលការរលាកជាដើម។ ដូចគ្នាទៅនឹងទីតាំងអាជីវកម្មនិងទីតាំងរដ្ឋាភិបាលដទៃទៀតដែរ នៅពេលដែលបុគ្គលិកថែទាំសុខភាពដឹងមិនច្បាស់ថាសត្វនោះជាសត្វនាំផ្លូវ ពួកគេអាចសាកសួរម្ចាស់សត្វថាតើតម្រូវឲ្យមានសត្វនាំផ្លូវដែរឬទេ ដោយសារតែពិការភាពណាមួយ ហើយតើកិច្ចការអ្វីខ្លះដែលសត្វនោះផ្ដល់ឲ្យ ប៉ុន្តែអាចនឹងមិនតម្រូវឲ្យមានលិខិតបញ្ជាក់ឬឯកសារផ្សេងទៀតស្ដីពីស្ថានភាពរបស់សត្វនាំផ្លូវនោះទេ។

## តើខ្ញុំអាចត្រូវបានតម្រូវឲ្យបង់ប្រាក់កក់សម្រាប់សត្វចិញ្ចឹមដើម្បីស្នាក់នៅសណ្ឋាគារជាមួយសត្វនាំផ្លូវរបស់ខ្ញុំដែរឬទេ?

ទេ។ ស្ថាប័នអាជីវកម្មនិងស្ថាប័នរដ្ឋាភិបាល មិនអាចតម្រូវឲ្យបុគ្គលដែលមានពិការភាពបង់ប្រាក់កក់ ឬបង់ប្រាក់បន្ថែមដើម្បីឲ្យមានសត្វនាំផ្លូវនៅជាមួយនោះទេ បើទោះបីជាវាជាគោលការណ៍របស់ពួកគេសម្រាប់សត្វចិញ្ចឹមក៏ដោយ។ ប៉ុន្តែ ប្រសិនបើទីកន្លែងស្នាក់នៅសាធារណៈឬស្ថាប័នសាធារណៈ ជាធម្មតាគិតថ្លៃពីអ្នកស្នាក់នៅរបស់ពួកគេសម្រាប់ការខូចខាតដែលបានកើតមានចំពោះ ទីតាំងដូចជាបន្ទប់សណ្ឋាគារជាដើម វាអាចគិតថ្លៃពីម្ចាស់របស់សត្វនាំផ្លូវសម្រាប់ការខូចខាតប្រហាក់ប្រហែលគ្នានេះ។

## តើសិទ្ធិរបស់ខ្ញុំមានអ្វីខ្លះ ខណៈពេលដែលខ្ញុំកំពុងបង្វឹកសត្វឆ្កែរបស់ខ្ញុំដើម្បីឲ្យក្លាយជាសត្វនាំផ្លូវ?

ច្បាប់សិទ្ធិពលរដ្ឋអ៊ុនរូហ៍របស់រដ្ឋកាលីហ្វ័រញ៉ា (California's Unruh Civil Rights Act) ក្រមរដ្ឋប្បវេណី មាត្រា 54.1 (Civil Code Section 54.1) និងច្បាប់ស្ដីពីបុគ្គលដែលមានពិការភាព (Disabled Persons Act) ក្រមរដ្ឋប្បវេណី មាត្រា 54.2 (Civil Code Sections 54.2) អនុញ្ញាតឲ្យមនុស្សដែលមានពិការភាពនាំយកសត្វឆ្កែចូល

ក្នុងលំនៅដ្ឋានជួលនិងអាជីវកម្មដទៃទៀត សម្រាប់គោលបំណងធ្វើការបង្វឹកពួកវាឲ្យក្លាយជាសត្វឆ្កែនាំផ្លូវ។

សត្វឆ្កែត្រូវតែពាក់ស្លាកដែលបានចេញដោយខោនធី ដែលបង្ហាញថាពួកវាជាសត្វឆ្កែនាំផ្លូវដែលកំពុងស្ថិតនៅក្នុងការបង្វឹក និងត្រូវតែដាក់ចងខ្សែ។ ប្រសិនបើមិនមានស្លាកដែលបានចេញដោយខោនធីនោះទេ សត្វឆ្កែនាំផ្លូវដែលស្ថិតនៅក្នុងការបង្វឹកនោះនៅតែអាចត្រូវបានស្នើសុំសម្រាប់ជាសេវាជំនួយសមស្របដដែល។

## ប្រសិនបើខ្ញុំមានសត្វគាំពារផ្លូវចិត្ត និងមិនមែនជាសត្វនាំផ្លូវនោះទេ តើច្បាប់ទាក់ទងនឹងទីសាធារណៈដូចគ្នានេះ អនុវត្តដែរឬទេ?

ទេ ច្បាប់ ADA ចែងថា មានតែសត្វនាំផ្លូវតែប៉ុណ្ណោះ និងមិនមែនសត្វគាំពារផ្លូវចិត្តទេ ដែលត្រូវបានអនុញ្ញាតឲ្យអមដំណើរជាមួយម្ចាស់របស់ពួកគេនៅទីសាធារណៈ ហើយវាមិនមានច្បាប់រដ្ឋឬសហព័ន្ធផ្សេងទៀតដែលអនុញ្ញាតឲ្យសត្វគាំពារផ្លូវចិត្តនៅទីសាធារណៈនោះទេ។

## តើខ្ញុំមានសិទ្ធិអ្វីខ្លះដើម្បីចូលទៅកាន់លំនៅដ្ឋានជាមួយសត្វជំនួយ?

នៅក្នុងបរិបទលំនៅដ្ឋាននៃច្បាប់ស្តីពីសិទ្ធិជនពិការ សត្វនាំផ្លូវនិងសត្វគាំពារផ្លូវចិត្តត្រូវបានហៅជារួមថា "សត្វជំនួយ។"

ការចូលទៅកាន់លំនៅដ្ឋានជាមួយនឹងសត្វនាំផ្លូវ – រួមទាំងការចូលទៅកាន់ទីជម្រកសម្រាប់ជនគ្មានទីលំនៅ – ត្រូវបានធ្វើដូចគ្នាទៅនឹងការចូលទៅកាន់ទីសាធារណៈ (មើលសំណួរខាងលើ "តើខ្ញុំត្រូវធ្វើដូចម្តេចនៅពេលដែលមានការប៉ុនប៉ងចូលទៅទីសាធារណៈជាមួយនឹងសត្វនាំផ្លូវរបស់ខ្ញុំ/តើសំណួរអ្វីខ្លះដែលអាចនឹងត្រូវសួរមកកាន់ខ្ញុំ?" និង "តើនៅពេលណាដែលសត្វនាំផ្លូវរបស់ខ្ញុំត្រូវបានបដិសេធមិនឲ្យចូលទៅកាន់ទីសាធារណៈ?)

ការចូលទៅកាន់លំនៅដ្ឋានជាមួយនឹងសត្វគាំពារផ្លូវចិត្ត – រួមទាំងការចូលទៅកាន់ទីជម្រកសម្រាប់ជនគ្មានទីលំនៅ – ត្រូវបានអនុញ្ញាតសម្រាប់ជាការជួយសម្រួលដ៏សមស្របទៅដល់ម្ចាស់ផ្ទះ សមាគមម្ចាស់ផ្ទះ ឬគោលនយោបាយគ្មានសត្វចិញ្ចឹមរបស់ទីជម្រកសម្រាប់ជនគ្មានទីលំនៅ។ ដំណើរការការជួយសម្រួលដ៏សមស្រប រួមមានសំណួរពាក់ព័ន្ធយ៉ាងលម្អិតទៅនឹងតម្រូវការដែលពាក់ព័ន្ធនឹងពិការភាព ប្រសិនបើចូលទៅកាន់ទីតាំងជាមួយនឹងសត្វនាំផ្លូវ។ សូមមើលសំណួរខាងក្រោមសម្រាប់ការពន្យល់បន្ថែម។

## តើការជួយសម្រួលសមស្របគឺជាអ្វី?

ការជួយសម្រួលសមស្រប គឺជាករណីលើកលែងចំពោះច្បាប់ឬគោលនយោបាយ ដែលចាំបាច់ដើម្បីអនុញ្ញាតឲ្យមនុស្សដែលមានពិការភាពមានឱកាសស្មើគ្នាក្នុងការប្រើប្រាស់និងមានភាពរីករាយចំពោះលំនៅដ្ឋានរបស់ពួកគេ។

កាតព្វកិច្ចដើម្បីបង្កើតការជួយសម្រួលសមស្របរួមមានលក្ខខណ្ឌតម្រូវការដែលអ្នកផ្តល់សេវាលំនៅដ្ឋានធ្វើការលើកលែងចំពោះគោលនយោបាយ “គ្មានសត្វចិញ្ចឹម” ដើម្បីអនុញ្ញាតឲ្យបុគ្គលដែលមានពិការភាពប្រើប្រាស់និងរស់នៅជាមួយសត្វគាំពារផ្លូវចិត្តរបស់ពួកគេ។

ក្រោមច្បាប់នៃរដ្ឋកាលីហ្វ័រញ៉ានិងច្បាប់សហព័ន្ធ សត្វគាំពារផ្លូវចិត្តត្រូវតែអនុញ្ញាតឲ្យនៅក្នុងលំនៅដ្ឋានសម្រាប់ជាការជួយសម្រួលសមស្របទៅដល់ពិការភាពរបស់អ្នកជួល។

### តើសត្វជំនួយរបស់ខ្ញុំចាំបាច់ត្រូវធ្វើការបញ្ជាក់ដើម្បីទទួលបានការជួយសម្រួលសមស្របទៅនឹងគោលនយោបាយគ្មានសត្វចិញ្ចឹមដែរឬទេ?

ទេ។ គ្មានការតម្រូវឲ្យសត្វជំនួយទទួលបានបង្វឹកឬបញ្ជាក់ជាពិសេសដើម្បីឲ្យមានការអនុញ្ញាតសម្រាប់ជាការជួយសម្រួលសមស្របនៅក្នុងលំនៅដ្ឋាននោះទេ។
ត្រូវតែមានទំនាក់ទំនងរវាងពិការភាពរបស់បុគ្គលនិងសេវាកម្ម ការលួងលោមឬភាពសិទ្ធស្នាលដែលសត្វផ្តល់ឲ្យ។

ចំណាំ - សត្វគ្រប់ប្រភេទអាចជាសត្វជំនួយដរាបណាវាកាត់បន្ថយរោគសញ្ញានៃពិការភាពរបស់ម្ចាស់។

### តើនៅពេលណាទើបសំណើសុំការជួយសម្រួលសមស្របរបស់ខ្ញុំដើម្បីមានសត្វជំនួយផ្លូវចិត្តនៅជាមួយខ្ញុំក្នុងលំនៅដ្ឋាន អាចត្រូវបានបដិសេធ?

ប្រសិនបើសត្វ៖

1. មិនចាំបាច់ដោយសារតែពិការភាពរបស់ម្ចាស់សត្វ
2. បង្កការគំរាមកំហែងដោយផ្ទាល់ដល់អ្នកដទៃឬទ្រព្យសម្បត្តិផ្សេងៗ
3. មិនស្ថិតនៅក្រោមការថែទាំរបស់ម្ចាស់សត្វ ឬមិនត្រូវបានបង្វឹកឲ្យនោមឬជុះនៅក្រៅផ្ទះ
4. ដាក់បន្ទុកផ្នែកហិរញ្ញវត្ថុនិងរដ្ឋបាលច្រើនហួសហេតុ ឬ
5. កែសម្រួលជាមូលដ្ឋាននូវលក្ខណៈនៃសេវាកម្មដែលម្ចាស់ផ្ទះ ឬសមាគមម្ចាស់ផ្ទះផ្តល់ឲ្យ។

ចំណាំ៖ សូមចាំថា ការគំរាមកំហែងដោយផ្ទាល់ត្រូវតែកំណត់ដោយការវាយតម្លៃនីមួយៗនូវអាកប្បកិរិយារបស់សត្វ មិនមែនជាការកំណត់ពាក់ព័ន្ធនឹងពូជសត្វនោះទេ។

ចំណាំ៖ ម្ចាស់សត្វក៏ត្រូវតែធានាថា សត្វជំនួយរបស់ពួកគេអនុវត្តតាមច្បាប់នៃការគ្រប់គ្រងសត្វរបស់រដ្ឋនិងតំបន់ និងមិនមានគ្រោះថ្នាក់ឬរំខានទៅដល់សហគមន៍ឡើយ។

ច្បាប់នេះរួមមានការចាក់ថ្នាំបង្ការថ្មីៗនេះ។ (សូមមើលចំណីអាហារនិងកសិកម្ម រដ្ឋកាលីហ្វ័រញ៉ា Code § 30851។)

### តើអ្វីដែលជាឧទាហរណ៍ស្តីពីការកែសម្រួលជាមូលដ្ឋាននូវលក្ខណៈនៃសេវាកម្មដែលម្ចាស់ផ្ទះ ឬសមាគមម្ចាស់ផ្ទះ ឬទីជម្រកសម្រាប់ជនគ្មានទីលំនៅផ្តល់ឲ្យ?

ការស្នើសុំឲ្យអ្នកផ្តល់សេវាលំនៅដ្ឋានឲ្យចំណីបណ្តើរ ឬសម្អាតនៅពីក្រោយសត្វនាំផ្លូវ អាចនឹងត្រូវបានចាត់ទុកជាការកែប្រែជាមូលដ្ឋានចំពោះសេវាកម្មដែលម្ចាស់ផ្ទះ ឬបុគ្គលិកនៃលំនៅដ្ឋានសម្រាប់ជនគ្មានទីលំនៅផ្តល់ឲ្យ។

### តើខ្ញុំត្រូវធ្វើការស្នើសុំការជួយសម្រួលសមស្របយ៉ាងដូចម្តេច?

អ្នកអាចធ្វើការស្នើសុំដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ [មើលខាងក្រោមសម្រាប់គំរូលិខិត]។

### តើសំណួរអ្វីខ្លះដែលអ្នកផ្តល់សេវាលំនៅដ្ឋានរបស់ខ្ញុំអាចនឹងសួរមកខ្ញុំ នៅពេលដែលស្នើសុំការជួយសម្រួលសមស្របចំពោះគោលនយោបាយគ្មានសត្វចិញ្ចឹមរបស់ពួកគេ?

ប្រសិនបើអ្នកកំពុងស្វែងរកការជួយសម្រួលសមស្របសម្រាប់សត្វជំនួយក្នុងលំនៅដ្ឋាន ម្ចាស់ផ្ទះ សមាគមម្ចាស់ផ្ទះ ឬអ្នកគ្រប់គ្រងទីជម្រកអាចៈ

1. ស្នើសុំឯកសារដែលអ្នកមានពិការភាព ហើយ
2. ដែលអ្នកមានតម្រូវការពាក់ព័ន្ធនឹងពិការភាពសម្រាប់សត្វនោះ។

ចំណាំៈ អ្នកផ្តល់សេវាលំនៅដ្ឋានមិនគួរស្នើសុំឯកសារទេ ប្រសិនបើពិការភាពរបស់អ្នក និងតម្រូវការពាក់ព័ន្ធនឹងពិការភាពរបស់អ្នកសម្រាប់សត្វនាំផ្លូវឬគាំពារ មានភាពជាក់ស្តែង។

អ្នកផ្តល់សេវាលំនៅដ្ឋានអាចស្នើសុំព័ត៌មានពីភាគីទីបីដែលអាចទុកចិត្តបាន ដូចជាអ្នកជំនាញផ្នែកព្យាបាលជាដើម ដើម្បីគាំទ្រដល់តម្រូវការសត្វជំនួយសម្រាប់ជាសេវាជំនួយសមស្រប។ ការស្នើសុំគប្បីត្រូវបានកំណត់ត្រឹមព័ត៌មានដែលចាំបាច់សម្រាប់បង្កើតតម្រូវការដែលពាក់ព័ន្ធនឹងពិការភាព។

<u>អ្នកផ្តល់សេវាលំនៅដ្ឋាន អាចនឹងមិនស្នើសុំអ្នកដាក់ពាក្យស្នើសុំឬអ្នកជួលលំនៅដ្ឋានឲ្យផ្តល់ការចូលទៅប្រើប្រាស់របាយការណ៍វេជ្ជសាស្ត្រឬអ្នកផ្តល់សេវាវេជ្ជសាស្ត្រនោះទេ ឬផ្តល់ព័ត៌មានលម្អិតឬទូលំទូលាយ ឬឯកសារស្តីពីពិការភាពផ្នែករាងកាយឬផ្លូវចិត្តរបស់បុគ្គលណាម្នាក់ឡើយ។</u>

*គំរូនៃលិខិតស្នើសុំនិងគាំទ្រសម្រាប់សត្វជំនួយ មាននៅខាងក្រោម។

## តើខ្ញុំអាចត្រូវបានតម្រូវឲ្យបង់ប្រាក់ដើម្បីរក្សាសត្វជំនួយឲ្យនៅជាមួយខ្ញុំដែរឬទេ?

ទេ។ អ្នកផ្ដល់សេវាលំនៅដ្ឋាន អាចនឹងមិនតម្រូវឲ្យអ្នកដាក់ពាក្យស្នើសុំឬអ្នកជួលធ្វើការបង់ប្រាក់ ឬប្រាក់កក់ធានា ឬទិញធានារ៉ាប់រងសម្រាប់សត្វដែលជាលក្ខខណ្ឌនៃការអនុញ្ញាតឲ្យបុគ្គលរក្សាទុកសត្វជំនួយនោះទេ។ ប៉ុន្តែ អ្នកផ្ដល់សេវាលំនៅដ្ឋាន អាចគិតថ្លៃពីបុគ្គលនោះសម្រាប់ការជួសជុលការខូចខាតនានាដែលសត្វបង្កឡើងទៅលើបន្ទប់ឬទីតាំងរួម។

## តើខ្ញុំអាចដាក់ពាក្យបណ្ដឹងយ៉ាងដូចម្ដេច ប្រសិនបើខ្ញុំជឿជាក់ថាខ្ញុំត្រូវបានរើសអើងដោយស្ថាប័នសាធារណៈ ឬកន្លែងទាំងឡាយដែលជាទីសាធារណៈ?

ប្រសិនបើអ្នកជឿជាក់ថា អ្នកត្រូវបានស្ថាប័ន អាជីវកម្មឬស្ថាប័នសាធារណៈរើសអើងដោយអយុត្តិធម៌ព្រោះតែសត្វនាំផ្លូវរបស់អ្នកស្ថាប័ន អ្នកអាចដាក់ពាក្យបណ្ដឹងជាមួយនឹងក្រសួងយុត្តិធម៌ (Department of Justice, DOJ)។ ប្រសិនបើពាក្យបណ្ដឹងគឺប្រឆាំងនឹងស្ថាប័នរដ្ឋាភិបាលឬស្ថាប័នឯកជនដែលទទួលបានមូលនិធិសហព័ន្ធ នោះពាក្យបណ្ដឹងត្រូវតែបានទទួលក្នុងអំឡុងពេល 180 ថ្ងៃបន្ទាប់ពីហេតុការណ៍នៃការរើសអើងនោះ (នៅពេលដែលបញ្ហាបានកើតឡើង)។ មិនមានកាលបរិច្ឆេទកំណត់សម្រាប់ការដាក់ពាក្យបណ្ដឹងប្រឆាំងនឹងអាជីវកម្មនៅក្រោមច្បាប់ ADA ដែលមិនទទួលបានមូលនិធិសហព័ន្ធទេ ប៉ុន្តែ ល្អបំផុតត្រូវដាក់ពាក្យបណ្ដឹងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ព័ត៌មានបន្ថែមអំពីរបៀបដាក់ពាក្យបណ្ដឹងជាមួយក្រសួងយុត្តិធម៌ (Department of Justice) អាចរកបាននៅ [https://www.ada.gov/filing_complaint.htm](https://www.ada.gov/filing_complaint.htm) ឬតាមរយៈខ្សែទូរសព្ទនៃព័ត៌មានអំពីច្បាប់ ADA លេខ (800) 514-0301 (សំឡេង) (800) 514-0383 (TTY)។

អ្នកក៏អាចដាក់ពាក្យបណ្ដឹងរដ្ឋបាលប្រឆាំងនឹងទីកន្លែងស្នាក់នៅសាធារណៈ ស្ថាប័នសាធារណៈ ឬអ្នកផ្ដល់សេវាលំនៅដ្ឋាន (រួមទាំងទីជម្រកសម្រាប់ជនដែលគ្មានទីលំនៅផងដែរ) សម្រាប់ការរើសអើងពីពិការភាពក្រោមច្បាប់របស់រដ្ឋកាលីហ្វ័រញ៉ា ទៅកាន់នាយកដ្ឋានលំនៅដ្ឋាននិងការងារស្មើភាពគ្នារដ្ឋកាលីហ្វ័រញ៉ា (California Department of Fair Employment and Housing, DFEH) ក្នុងអំឡុងពេលមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទចុងក្រោយនៃការរើសអើងនេះ។ ព័ត៌មានបន្ថែមអំពីរបៀបដាក់ពាក្យបណ្ដឹងជាមួយ DFEH អាចរកបាននៅ [https://www.dfeh.ca.gov/filing-a-complaint-online/](https://www.dfeh.ca.gov/filing-a-complaint-online/) ឬដោយទូរសព្ទទៅលេខ (800) 884-1684 (សំឡេង) ឬ (800) 700-2320 (TTY)។

ក្រៅពីនេះ ឬបន្ថែមពីលើការដាក់ពាក្យបណ្ដឹងទៅកាន់ DOJ ឬ DFEH អ្នកអាចដាក់បណ្ដឹងផ្លូវច្បាប់ទៅកាន់តុលាការរដ្ឋ ឬតុលាការសហព័ន្ធសម្រាប់ការលើកលែងពីបញ្ហានិងការប្រកាសនៅក្រោមច្បាប់សហព័ន្ធឬច្បាប់រដ្ឋ។ សំណងខូចខាតជាប្រាក់ អាចស្វែងរកបាននៅក្រោមច្បាប់រដ្ឋ រួមទាំងសំណងខូចខាតតាមច្បាប់ជាអប្បបរមាចំនួន $4,000 ក្នុងហេតុការណ៍នៃការរើសអើងមួយលើក។ ក្រមរដ្ឋប្បវេណី §52។ ការប្ដឹងត្រូវធ្វើឡើងក្នុងអំឡុងពេលពីរឆ្នាំបន្ទាប់ពីហេតុការណ៍នៃការរើសអើងនោះ។

ប្រសិនបើអ្នកស្វែងរកសំណងខូចខាតជាទឹកប្រាក់តិចជាង $10,000 នោះ ជម្រើសមួយទៀតគឺត្រូវដាក់ពាក្យបណ្ដឹងករណីរើសអើងទៅកាន់តុលាការសម្រាប់បណ្ដឹងតូចតាចក្នុងមូលដ្ឋាន។ អាជ្ញាយុកាលដែលបានពិភាក្សាខាងលើ នឹងត្រូវអនុវត្ត។ អ្នកមិនអាចប្រើមេធាវីបានទេ ក្នុងករណីអ្នកប្ដឹងនៅតុលាការសម្រាប់បណ្ដឹងតូចតាចក្នុងមូលដ្ឋាននោះ។ **នេះគឺជាតំណភ្ជាប់** ទៅកាន់ឯកសារបោះពុម្ពផ្សាយសិទ្ធិពិការភាពរដ្ឋកាលីហ្វ័រញ៉ា ដែលពន្យល់ពីដំណើរការនីតិវិធីនៃការប្រើប្រាស់បណ្ដឹងតូចតាចសម្រាប់ករណីរើសអើង។

បន្ថែមលើនេះទៀត ច្បាប់ស្ដីពីបណ្ដឹងចំពោះការប្រព្រឹត្តខុសរបស់រដ្ឋាភិបាល (Government Tort Claims Act) តម្រូវឲ្យដាក់ពាក្យបណ្ដឹងចំពោះការប្រព្រឹត្តខុសរបស់រដ្ឋាភិបាល ក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីមានហេតុការណ៍រើសអើងនេះ មុននឹងដាក់បណ្ដឹងទាមទារសំណងការខូចខាតជាប្រាក់ប្រឆាំងនឹងស្ថាប័នរដ្ឋាភិបាលមូលដ្ឋាននិងរដ្ឋ។ សម្រាប់ព័ត៌មានបន្ថែមស្ដីពីបណ្ដឹងចំពោះការប្រព្រឹត្តខុស អាចរកបាននៅ **តំណភ្ជាប់នេះ** សូមកត់សម្គាល់ថាតំណភ្ជាប់ទៅកាន់ទម្រង់ពាក្យបណ្ដឹងតវ៉ាទៅនឹងរដ្ឋឬទីភ្នាក់ងាររដ្ឋ ឬនិយោជិតនៅលើគេហទំព័រនេះ អាចនឹងមិនអនុវត្តបានឡើយក្នុងករណីរបស់អ្នក។ ស្ថាប័នសាធារណៈដទៃផ្សេងទៀត អាចមាននូវពាក្យបណ្ដឹងរបស់ខ្លួនដែលអាចរកបាននៅលើគេហទំព័ររបស់គេ។ ប្រសិនបើអ្នកចង់បន្តបណ្ដឹងនោះ អ្នកគួរតែពិភាក្សាជាមួយមេធាវីឲ្យបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន។

### តើខ្ញុំអាចដាក់ពាក្យបណ្ដឹងយ៉ាងដូចម្ដេច ប្រសិនបើខ្ញុំជឿជាក់ថាខ្ញុំត្រូវបានរើសអើងដោយអ្នកផ្ដល់សេវាលំនៅដ្ឋាន?

ប្រសិនបើម្ចាស់ផ្ទះ សមាគមខុនដូ ឬអ្នកផ្ដល់សេវាលំនៅដ្ឋានដទៃទៀត បដិសេធក្នុងការអនុញ្ញាតឲ្យសត្វជំនួយរបស់អ្នកសម្រាប់ជាការជួយសម្រួលសមស្រប អ្នកអាចដាក់ពាក្យបណ្ដឹងឬបណ្ដឹងរដ្ឋបាលបាន។

អ្នកអាចដាក់បណ្ដឹងរដ្ឋបាលទៅកាន់នាយកដ្ឋានលំនៅដ្ឋាននិងការងារស្មើភាពគ្នារដ្ឋកាលីហ្វ័រញ៉ា (California Department of Fair Employment and Housing, DFEH) ក្នុងរយៈពេលមួយឆ្នាំបន្ទាប់កាលបរិច្ឆេទនៃការរើសអើងដែលថ្មីៗបំផុត។ ព័ត៌មានអំពីរបៀបដាក់ពាក្យបណ្ដឹងទៅកាន់ DFEH អាចរកបាននៅ **https://www.dfeh.ca.gov/filing-a-complaint-online/** ឬដោយទូរសព្ទទៅលេខ (800) 884-1684 (សំឡេង) ឬ (800) 700-2320 (TTY)។

អ្នកអាចដាក់ពាក្យបណ្ដឹងរដ្ឋបាលទៅកាន់ក្រសួងលំនៅដ្ឋាននិងអភិវឌ្ឍន៍ជនបទសហរដ្ឋអាមេរិក (U.S. Department of Housing and Urban Development, HUD) ក្រោមច្បាប់វិសោធនកម្មច្បាប់ស្ដីពីលំនៅដ្ឋានស្មើភាពគ្នា (Fair Housing Amendments Act) ក៏ក្នុងអំឡុងពេលមួយឆ្នាំបន្ទាប់ពីការរើសអើងនោះ។ ព័ត៌មានអំពីរបៀបដាក់ពាក្យបណ្ដឹង HUD អាចរកបានតាមរយៈលេខ 1-800-669-9777 ឬ៖ **https://portal.hud.gov/hudportal/HUD?src=/topics/housing_discrimination**.

ការរំលោភច្បាប់ដែលបានពិភាក្សាខាងលើ ក៏អាចពង្រឹងការអនុវត្តច្បាប់តាមរយៈពាក្យបណ្ដឹងជាលក្ខណៈឯកជនផងដែរ។ សូមមេត្តាជ្រាបថា អាជ្ញាយុកាលរឹតបន្តឹងចំពោះពេលវេលាសម្រាប់ការដាក់បណ្ដឹងវិវាទនេះ ហើយចាំថាអ្នកអាចបាត់បង់ឱកាសក្នុងការទាមទារ ប្រសិនបើអ្នកពុំបានចាត់វិធានការក្នុងអំឡុងពេលនៃអាជ្ញាយុកាលជាធរមាននេះទេ។ កាលបរិច្ឆេទទាំងនេះ អាចមានរយៈពេលខ្លីត្រឹមពីរឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃសកម្មភាពរើសអើងត្រូវបានប្រព្រឹត្តឡើង។ ប្រសិនបើអ្នកចង់បន្តបណ្ដឹងនោះ អ្នកគួរតែពិភាក្សាជាមួយមេធាវីឲ្យបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន។

ប្រសិនបើអ្នកស្វែងរកសំណងខូចខាតជាទឹកប្រាក់តិចជាង $10,000 នោះ ជម្រើសមួយទៀតគឺត្រូវដាក់ពាក្យបណ្ដឹងករណីរើសអើងទៅកាន់តុលាការសម្រាប់បណ្ដឹងតូចតាចក្នុងមូលដ្ឋាន។ អាជ្ញាយុកាលដែលពិភាក្សាខាងលើ នឹងត្រូវអនុវត្ត។ អ្នកមិនអាចប្រើមេធាវីបានទេ ក្នុងករណីអ្នកប្ដឹងនៅតុលាការសម្រាប់បណ្ដឹងតូចតាចក្នុងមូលដ្ឋាននោះ។ សម្រាប់ព័ត៌មានបន្ថែមសូមមើលសិទ្ធិពិការភាពរដ្ឋកាលីហ្វ័រញ៉ា (Disability Rights California) ការណែនាំទៅកាន់តុលាការសម្រាប់បណ្ដឹងតូចតាចក្នុងមូលដ្ឋាន៖ របៀបប្ដឹង ក្នុងករណីអាជីវកម្មឬម្ចាស់ផ្ទះរើសអើងជាមួយអ្នកដោយសារតែពិការភាពរបស់អ្នក តាមរយៈ៖ **https://www.disabilityrightsca.org/publications/a-guide-to-small-claims-court-how-to-sue-if-a-business-or-landlord-discriminates**

## គំរូលិខិតទៅកាន់អ្នកផ្តល់សេវាលំនៅដ្ឋានដើម្បីស្នើសុំសត្វជំនួយ

[កាលបរិច្ឆេទ]

ជូនចំពោះ [ម្ចាស់ផ្ទះ អាជ្ញាធរលំនៅដ្ឋាន សមាគមម្ចាស់ផ្ទះ ឈ្មោះនៃលំនៅដ្ឋានសម្រាប់ជនគ្មានទីលំនៅ]

ខ្ញុំបាទ/នាងខ្ញុំសរសេរលិខិតនេះដើម្បីស្នើសុំឲ្យមានសត្វជំនួយសម្រាប់ជាការជួយសម្រួលសមស្របចំពោះបញ្ហាពិការភាពរបស់ខ្ញុំ។

ខ្ញុំរស់នៅ/កំពុងដាក់ពាក្យស្នើសុំជួលទ្រព្យរបស់អ្នក/ស្នាក់នៅ [អាសយដ្ឋាន]។ ដោយសារតែពិការភាពរបស់ខ្ញុំ
ខ្ញុំត្រូវការរក្សាទុកសត្វជំនួយសម្រាប់ជាការជួយសម្រួលសមស្រប។

គ្រូពេទ្យ/គ្រូពេទ្យផ្នែកសរសៃប្រសាទ/អ្នកចិត្តសាស្ត្រ/គ្រូពេទ្យព្យាបាល/បុគ្គលិកសង្គមកិច្ច/គ្រូពេទ្យព្យាបាលសម្បទាវិជ្ជាជីវៈ/បុគ្គលដទៃទៀត [សូមរៀបរាប់] បានកំណត់ថា ការជួយសម្រួលនេះមានសារៈសំខាន់ណាស់ពាក់ព័ន្ធនឹងពិការភាពរបស់ខ្ញុំ។ សូមមេត្តាពិនិត្យលិខិតដូចបានភ្ជាប់មកជាមួយពី [ឈ្មោះវេជ្ជបណ្ឌិតឬអ្នកជំនាញ]។

ច្បាប់សហព័ន្ធនិងច្បាប់រដ្ឋ តម្រូវឲ្យអ្នកផ្តល់សេវាលំនៅដ្ឋានផ្តល់ជំនួយគាំទ្រសមស្របជូនអ្នកជួល/អ្នកស្នាក់នៅ និងអ្នកដាក់ពាក្យសុំដែលមានពិការភាព។ សូមមេត្តាឆ្លើយតបចំពោះសំណើនេះឲ្យបានត្រឹមថ្ងៃ [កាលបរិច្ឆេទ]។ សូមទាក់ទងមកកាន់ខ្ញុំតាមរយៈលេខ [លេខទូរសព្ទរបស់អ្នក និង/ឬអាសយដ្ឋានអ៊ីម៉ែល] ប្រសិនបើអ្នកមានសំណួរណាមួយ។ សូមអរគុណ។

ដោយសេចក្តីគោរពអំពីខ្ញុំ

[ឈ្មោះរបស់អ្នក]

[អាសយដ្ឋានរបស់អ្នក]

## គំរូលិខិតបញ្ជាក់អះអាង

[កាលបរិច្ឆេទ]

ជូនចំពោះ [ម្ចាស់ផ្ទះ អាជ្ញាធរលំនៅដ្ឋាន សមាគមម្ចាស់ផ្ទះ ឈ្មោះទីជម្រកសម្រាប់ជនគ្មានទីលំនៅ]៖

ខ្ញុំគឺជាគ្រូពេទ្យ/គ្រូពេទ្យផ្នែកសរសៃប្រសាទ/អ្នកចិត្តសាស្ត្រ/គ្រូពេទ្យព្យាបាល/បុគ្គលិកសង្គមកិច្ច/គ្រូពេទ្យព្យាបាលសម្បទាវិជ្ជាជីវៈសម្រាប់ [ឈ្មោះរបស់អ្នក] ហើយខ្ញុំបានដឹងអំពីស្ថានភាពរបស់គាត់។ គាត់មានពិការភាពដែលនាំមកនូវបញ្ហាមិនអាចបំពេញមុខងារមួយចំនួនបាន។ បញ្ហាទាំងនេះរួមមាន [រៀបរាប់ពីបញ្ហាមិនអាចបំពេញមុខងារបាន ដែលតម្រូវឲ្យមានការជួយសម្រួលដែលបានស្នើសុំនេះ]។

សត្វជំនួយគឺចាំបាច់សម្រាប់_____ ដើម្បីរស់នៅក្នុងសហគមន៍ និងប្រើប្រាស់ និងរីករាយជាមួយនឹងការស្នាក់នៅរបស់គាត់ដោយ [រៀបរាប់ពីរបៀបដែលសត្វនេះនឹងផ្តល់ជំនួយឬគាំទ្រ]។

សូមអរគុណសម្រាប់ការផ្តល់ការជួយសម្រួលសមស្របសម្រាប់ [ឈ្មោះ]។

ដោយសេចក្តីគោរពអំពីខ្ញុំ

[ឈ្មោះនិងមុខតំណែង]

## របៀបទទួលបានទំនាក់ទំនងជាមួយនឹងសិទ្ធិពិការភាពរដ្ឋកាលីហ្វ័រញ៉ា (Disability Rights California)

ប្រសិនបើអ្នកមានសំណួរបន្ថែម និងសម្រាប់ជំនួយផ្លូវច្បាប់ សូមហៅទូរសព្ទទៅ **សិទ្ធិពិការភាពរដ្ឋកាលីហ្វ័រញ៉ា (Disability Rights California)** តាមរយៈលេខ 800-776-5746 ឬបំពេញ **ទម្រង់បែបបទស្នើសុំជំនួយ**។ សម្រាប់គោលបំណងផ្សេងទៀតទាំងអស់ សូមហៅទូរសព្ទទៅកាន់លេខ 916-504-5800 (រដ្ឋកាលីហ្វ័រញ៉ាភាគខាងជើង) 213-213-8000 (រដ្ឋកាលីហ្វ័រញ៉ាភាគខាងត្បូង)។